# ធម្មទេសនារបស់លោកអភិបាលអូលីវីយេ
# អភិបូជាបុណ្យហែរព្រះកាយនៅចំការទៀង
# ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៨

*ខ្ញុំជាអាហារដែលផ្ដល់ជីវិត*

| |
|---|
| អត្ថបទទី១៖ សរ ២៤,៣-៨ |
| អត្ថបទទី២៖ ហប ៩,១១-១៥ |
| ដំណឹងល្អ៖ មក ១៤,១២-១៦.២២-២៦ |

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះយើងមកដើម្បីជប់លៀងជាមួយព្រះយេស៊ូ ព្រះអង្គមានព្រះបន្ទូលថា "**ខ្ញុំជាអាហារដែលផ្ដល់ជីវិត**"។ មនុស្សយើង ដើម្បីនៅរស់យើងត្រូវការហូបបាយ តែថ្ងៃនេះព្រះយេស៊ូយាងមកដើម្បីប្រទានអាហារដែលផ្ដល់ជីវិត គឺព្រះយេស៊ូផ្ទាល់។ គ្រប់ពេលយើងចូលអភិបូជា ណែនាំឲ្យយើងយល់ថាព្រះយេស៊ូយាងមកដើម្បីប្រទានអាហារដែលផ្ដល់ជីវិត។ យើងគោរព វត្តមានរបស់ព្រះយេស៊ូដែលគង់នៅជាមួយយើង នៅពេលយើងទទួលព្រះកាយដែលជានំគ្មានរសជាតិ ជានំដែលគ្មានមេ គ្មានអំបិល គ្មានស្ករ ប៉ុន្តែនៅក្នុងនំនេះមានវត្តមានរបស់ព្រះយេស៊ូពិតៗ។ តើយើងធ្វើដូចម្ដេច ដើម្បីដឹងថាមានវត្តមានរបស់ព្រះយេស៊ូពិតៗ? ពេលលោកបូជាចារ្យបានសុំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យនំនេះទៅជាព្រះកាយ សុំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធណែនាំឲ្យស្រានេះទៅជាព្រះលោហិត។ ដូច្នេះ ពេលយើងទទួលនំនេះ វាមិនមែនជានំធម្មតាព្រោះវាមានវត្តមានរបស់ព្រះយេស៊ូដ៏ពេញលក្ខណៈ។

សន្តិតេរេសា ពេលគាត់នៅក្មេងរាល់អាទិត្យគាត់ចូលជាមួយឪពុកម្ដាយ គាត់ចង់ទទួលនំហ្នឹងណាស់ គាត់សុំទទួលមុនអាយុ៦ឆ្នាំ។ ពេលដល់គ្រប់អាយុអាចទទួលបានព្រះកាយបាន ពីរយប់មុនគាត់សម្រាកមិនលក់ នៅពេលគាត់ហែដើម្បីទទួលព្រះកាយគាត់យល់ថា "**ថ្ងៃនេះព្រះយេស៊ូមកថើបខ្ញុំ**"។ វត្តមានរបស់ព្រះយេស៊ូ ណែនាំឲ្យគាត់យល់ថាមានភាពជិតស្និទ្ធ ដូចជាព្រះយេស៊ូបានឱបគាត់និងថើបគាត់ទៀង។ ខ្ញុំជាអាហារដែលផ្ដល់ជីវិត នៅក្នុងធម៌ឱព្រះបិតា យើងបានសូត្រថា "**សូមប្រទានអាហារជារៀងរាល់ថ្ងៃ**" អាហារដែលយើងទទួលថ្ងៃនេះតាមរយៈព្រះកាយព្រះគ្រីស្ដ ជាកម្លាំងសម្រាប់យើងដែលដើរតាមព្រះយេស៊ូ ដើម្បីអនុវត្តន៍ព្រះបន្ទូលរបស់ព្រះយេស៊ូ "**សូមប្រទានអាហារឲ្យគេដែរ**" នៅពេលព្រះអង្គនៅជាមួយមនុស្ស៥០០០នាក់លើភ្នំ។ ព្រះយេស៊ូបានយកនំប៉័ងប្រាំដុំ និងត្រីពីរកន្ទុយ សូមព្រះជាម្ចាស់ប្រទានពរលើនំប៉័ងនិងត្រីនេះ ធ្វើឲ្យព្រះអង្គអាចចិញ្ចឹមមនុស្សដ៏ច្រើនបែបនេះបាន។ យើងទទួលអាហារដែលផ្ដល់ជីវិតតាមរយៈព្រះយេស៊ូ ឲ្យយើងណែនាំបងប្អូនឯទៀតៗដែលកំពុងស្រេកឃ្លានឲ្យគេមានម្ហូបអាហារ។ ជាពិសេសនៅក្នុងប្រទេសយើង មានមនុស្សយ៉ាងច្រើនដែលគ្មានម្ហូបប្រចាំថ្ងៃ។

ក្នុងសិទ្ធិកុមារ មានមាត្រាមួយចំនួនដែលយើងត្រូវតែចងចាំ ដូចជា ឲ្យមានឪពុកម្ដាយដែលយើងគេ ឲ្យមានផ្ទះស្នាក់នៅសមរម ឲ្យមានម្ហូបអាហារគ្រប់គ្រាន់ ឲ្យមានថ្នាំព្យាបាល ឲ្យយើងមានសាលាទៅរៀន ឲ្យយើងទៅដើរលេងនិងសប្បាយបាន...។ នៅក្នុងពិភពលោកទាំងមូល មានអយុត្តិធម៌ច្រើនណាស់រវាងតំបន់ដែលមានអ្នកមានដល់កំពូល និងមានអ្នកក្រីក្រ ណែនាំឲ្យយើងជាគ្រីស្ដបរិស័ទត្រូវការគិត **តើ**

**យើងធ្វើដូចម្តេចដើម្បីបង្កើតសង្គមដែលប្រកបដោយយុត្តិធម៌?** សូមឲ្យម្ហូបអាហារឲ្យគេ ជាពិសេសដល់កូនក្មេង ឲ្យគេមានផ្ទះស្នាក់នៅ សូមណែនាំឲ្យគេមានជីវិតថ្លៃថ្នូរ សូមណែនាំឲ្យគេមានជីវិតរស់នៅដូចគ្នាង។ សព្វថ្ងៃយើងមានបញ្ហានៅក្នុងពិភពលោក គឺភាពក្រីក្រ ដោយសារខ្វះការងារធ្វើ ខ្វះម្ហូបអាហារ ខ្វះកន្លែងស្នាក់នៅ បញ្ហាមួយទៀតគឺការផ្សព្វផ្សាយព័ត៌មានរបៀបថ្មី មានប្រជាជនមួយចំនួនដែឡអាចទទួលព័ត៌មានទាំងអស់ និងមានប្រជាជនមួយចំនួនទៀតមិនដឹងអ្វីសោះ។ នេះជាឧទាហរណ៍មួយ ដែលជាភាពអយុត្តិធម៌ដែលកំពុងកើតឡើងនៅក្នុងពិភពលោកសព្វថ្ងៃ។ សម្រាប់យើងជាគ្រីស្តបរិស័ទ យើងត្រូវការធ្វើយ៉ាងណា ដើម្បីឲ្យមនុស្សលោកទាំងអស់ ចូលនៅក្នុងសង្គមយ៉ាងសកម្ម ឲ្យយើងទាំងអស់អាចទទួលព័ត៌មាន ឲ្យយើងទាំងអស់អាចយល់គ្នាទៅវិញទៅមក។ ដូចនៅថ្ងៃទី០១មិថុនាកន្លងមក យើងមានកម្មវិធីទិវាកុមារអន្តរជាតិនៅភូមិសុខសាន្ត ដែលមានទាំងកូនមតេយ្យ ទាំងកូនបឋមសិក្សា ទាំងកូនពិការ ទាំងយុវជន ទាំងអ្នកក្រីក្រ ទាំងអ្នកមាន... ទាំងអស់គ្នានៅជាមួយគ្នាមួយព្រឹក យើងលែងគិតអំពីភាពខុសគ្នារបស់យើង តែធ្វើឲ្យយើងយល់ថាយើងជាមហាគ្រួសារតែមួយ ដែលចេះជួយគ្នាទៅវិញទៅមក ដែលបង្ហាញសេចក្តីស្រឡាញ់និងការគោរពគ្នាទៅវិញទៅមក។ យើងត្រូវការបង្កើតសង្គមរបៀបហ្នឹង ដែលបានបង្ហាញអំពីគម្រោងការរបស់ព្រះជាម្ចាស់សម្រាប់ពិភពលោក ដែលយើងអាចធ្វើបាន។

យើងអរព្រះគុណព្រះជាម្ចាស់ ដោយសារព្រះយេស៊ូមានវត្តមាន អរព្រះគុណព្រះជាម្ចាស់ដោយសារបន្តិចទៀតកូនយើងទទួលស្មានថើបមួយយ៉ាងពិសេសពីព្រះយេស៊ូផ្ទាល់ និងអរព្រះគុណព្រះជាម្ចាស់ ដោយសារយើងជាគ្រីស្តបរិស័ទបានខិតខំអនុវត្តន៍ ខ្ញុំជាអាហារដែលផ្តល់ជីវិតសម្រាប់មនុស្សទាំងអស់ឲ្យរស់នៅប្រកបដោយកិត្តិយស និងតម្លៃថ្លៃថ្នូរប្រចាំថ្ងៃ។ អាម៉ែន៕